**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**
លេខៈ ០៤៧៧/២០ ក.អ.ជ

ថ្ងៃព្រហស្បតិ៍ ១១ រោច ខែ ផល្គុន ឆ្នាំជូត ទោស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០២០

# របាយការណ៍
# វឌ្ឍនភាពការងារប្រចាំខែកុម្ភៈ និងទិសដៅការងារខែមីនា ឆ្នាំ ២០២០
# របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## ១.សេចក្តីផ្តើម

ការអនុវត្តផែនការសកម្មភាពប្រចាំខែកុម្ភៈ នៅមានកម្រិតតិចតួចនៅឡើយសម្រាប់សកម្មភាពទាំងឡាយដែលទាក់ទងនឹងការប្រើប្រាស់ថវិកាជាតិ។ អង្គភាពក្រោមឱវាទក្រសួងទាំងថ្នាក់កណ្តាល និងរាជធានី ខេត្ត បានចាប់ផ្តើមការងាររបស់ខ្លួននៅតាមមូលដ្ឋានជនបទយ៉ាងសស្រាក់សស្រាំទៅតាមផែនការឆ្នាំ២០២០ ដែលក្រសួងបានរៀបចំ និងកំណត់គោលដៅរួចជាស្រេច។ ការងារសាងសង់ជួសជុល ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍កំពុងរៀបចំឯកសារដេញថ្លៃ និងខ្លះកំពុងដំណើរការនៅតាមការដ្ឋានបណ្តើរៗហើយដើម្បីដោះស្រាយសំណូមពរ និងតម្រូវការប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។ ការឡើងកំដៅ និងរាំងស្ងួតនៅរដូវប្រាំងឆ្នាំនេះបានជះឥទ្ធិពលដល់ការងារបង្កបង្កើនផល ទឹកស្អាតសម្រាប់បរិភោគ និងទឹកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។ បញ្ហានេះក្រសួងបានយកចិត្តទុកដាក់ណែនាំដល់មន្ត្រីគ្រប់ជាន់ថ្នាក់ឲ្យត្រៀមលក្ខណៈ ដើម្បីចុះជួយប្រជាពលរដ្ឋនៅតំបន់ណាដែលបញ្ហាប្រឈមនឹងការខ្វះទឹក ហើយស្របពេលនេះដែរ ក្រសួងក៏បានបង្កើតលេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយ និងបានពិភាក្សាគ្នាចំនួន ០២ ដង រួចហើយដើម្បីត្រៀមលក្ខណៈសម្បត្តិក្នុងការចុះដោះស្រាយជូនប្រជាពលរដ្ឋនៅតាមជនបទ។ ការធ្វើអនាម័យខ្លួនប្រាណនៅតាមខ្នងផ្ទះនៅតាមសហគមន៍ ត្រូវបានក្រសួងយកចិត្តទុកដាក់ផ្សព្វផ្សាយជាប្រចាំ ពិសេសការប្រយុទ្ធប្រឆាំងនឹងមេរោគប្រភេទថ្មី COVID-19 និងការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល ODF និងបានអំពាវនាវឲ្យមានការចូលរួមរក្សាអនាម័យទាំងអស់គ្នា ដើម្បីជានាឲ្យបានសុខមាលភាពជូនប្រជាជនយើង ។

ការងារកែទម្រង់ក៏ជាផ្នែកសំខាន់ ដែលក្រសួងកំពុងយកចិត្តទុកដាក់ដែរ ដូចជាកំណែទម្រង់រដ្ឋបាលសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការក្នុងការផ្ទេរមុខងារ និងថវិកាទៅថ្នាក់ក្រោមជាតិ ។ ការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈត្រូវបានក្រសួងសហការជាមួយជំនាញការមកពី ADB និង EU ដើម្បីពិនិត្យនិងវាយតម្លៃលទ្ធផលដែលក្រសួងសម្រេចបានដើម្បីឈានទៅបន្តដំណាក់កាលទី៤ នៅពេលដ៏ខ្លីខាងមុខនេះ ដែលបានកំណត់ថា **ថវិកាសមិទ្ធកម្ម** លើកម្មវិធីរបស់ក្រសួង ។

លទ្ធផលដែលក្រសួងសម្រេចបានប្រចាំខែកុម្ភៈ ឆ្នាំ២០២០ នេះមានដូចខាងក្រោម៖



អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 884 639
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល dap.mrd@gmail.com

## ២.វឌ្ឍនភាព

### ២.១. លទ្ធផលរួមរបស់ក្រសួងអភិវឌ្ឍន៍ជនបទ

កម្មវិធីទាំង៤ របស់ក្រសួងដែលបានអនុម័តកាលពីឆ្នាំ ២០១៩ ត្រូវបានចាប់ផ្តើមអនុវត្តក្នុងឆ្នាំ ២០២០នេះ ដើម្បីសម្រេចគោលដៅនៃចក្ខុវិស័យជំរុញឲ្យមានការផ្លាស់ប្តូរជីវភាពរស់នៅដោយផ្ទាល់របស់ប្រជាជនជនបទប្រកបដោយបរិយាប័ន្ន ទាំងផ្នែកសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងបរិស្ថាន។ ក្នុងខែកុម្ភៈនេះ ក្រសួងទើបចាប់ផ្តើមដំណើរការសកម្មភាពបានតិចតួចប៉ុណ្ណោះ ។

### ២.២.លទ្ធផលរបស់អង្គភាពចំណុះក្រសួងអភិវឌ្ឍន៍ជនបទ

#### ២.២.១.ការងាររដ្ឋបាល និងបុគ្គលិក

ដោយគិតត្រឹមដំណាច់ខែកុម្ភៈ ឆ្នាំ២០២០ មន្ត្រីរាជការក្របខណ្ឌសរុបមានចំនួន ១ ៧៩២ នាក់ (ស្រី ៤៥៥ នាក់) ប្រៀបធៀបនឹងចំនួនមន្ត្រីរាជការកាលពីដំណាច់ខែមករា គឺមានការកើនឡើងចំនួន ០៣ នាក់ ដោយការផ្ទេរក្របខណ្ឌចូល។ ក្រសួងបានទទួលលិខិតចូលចំនួន ២២៣ ច្បាប់ លិខិតចេញក្រៅក្រសួងចំនួន ១៤៨ ច្បាប់ ចុះលេខប្រកាស និងសេចក្តីសម្រេចនានាចំនួន ១៨ ច្បាប់ និងចុះលេខលិខិតបេសកកម្មចំនួន ២៥៦ ច្បាប់ ។

#### ២.២.២.ការងារផ្គត់ផ្គង់ និងហិរញ្ញវត្ថុ

ក្នុងខែកុម្ភៈ នេះក្រសួងបានអនុវត្តចំណាយធៀបនឹងច្បាប់ហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០២០ សម្រេចបាន ៖

- ចំណាយចរន្តអនុវត្តបានចំនួន ១ ២៣៤ ៤០០ ៥៨០ រៀល ស្មើនឹង ០,៨៦% នៃច្បាប់ថវិកា
- ចំណាយមូលធនអនុវត្តបានចំនួន ៤៦២ ១៨០ ០០០ រៀល ស្មើនឹង ២,២៤% នៃច្បាប់ថវិកា ។

#### ២.២.៣. ការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- ចូលរួមកិច្ចប្រជុំពិនិត្យ និងពិភាក្សាអំពីការរៀបចំរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ ២០១៩ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចូលរួមប្រជុំពិភាក្សាពីតម្រូវការបណ្តុះបណ្តាលធនធានមនុស្សលើការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសហការជាមួយសកលវិទ្យាល័យលីក្វាន់យូរ នៅប្រទេសសឹង្ហបុរីនាពេលខាងមុខនេះ
- ចូលរួមកិច្ចប្រជុំ Kick-off meeting ជាមួយ EU ដើម្បីពិនិត្យ និងវាយតម្លៃលើការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងផែនការថវិកា នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចូលរួមកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងឯកសារទស្សនទាន ស្តីពីចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA) ឆ្នាំ២០២០ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចូលរួមកិច្ចប្រជុំបូកសរុប និងពិភាក្សាលទ្ធផល នៃដំណើរបេសកកម្មក្រុមជំនាញការរបស់ EU ស្តីពីការវិភាគពីសមានគតិភាពរវាងផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធី នៅទីស្តី

ការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- ឆ្លើយតបនឹងសំណួរ (Questionnaire Surveys) របស់ជំនាញការមកពីសហគមន៍អឺរ៉ុប (EU) លើការងារកែទម្រង់ដំណាក់កាលទី៣
- ត្រៀមរៀបចំសិក្ខាសាលាបណ្តុះបណ្តាលស្តីពី ការរៀបចំផែនការថវិកាកម្មវិធី ឆ្នាំ ២០២១ ឲ្យស្របនឹងរចនាសម្ព័ន្ធផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ ឆ្នាំ២០១៩-២០២៣ របស់ក្រសួងអភិវឌ្ឍន៍ជនបទនៅសណ្ឋាគារហ៊ីម៉ាវ៉ារី រាជធានីភ្នំពេញ
- ធ្វើបច្ចុប្បន្នភាព MAP3 ឆ្នាំ២០២០ និងកំណត់ KPIs ឡើងវិញ ។

### ២.២.៤. ក្រុមការងារបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការ

- រៀបចំផ្ទេរមុខងារក្នុងវិស័យអភិវឌ្ឍន៍ជនបទចំនួន ០៣ ដោយប្រគល់ទៅឲ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ទូទាំងព្រះរាជាណាចក្រកម្ពុជាចាប់ពី ឆ្នាំ២០២០ តទៅ ។

### ២.២.៥. ការងារផែនការ និងសហប្រតិបត្តិការអន្តរជាតិ

- ត្រួតពិនិត្យមើលឡើងវិញផែនការថវិកាឆ្នាំ២០២០ របស់ក្រសួងអភិវឌ្ឍន៍ជនបទ
- ជួបពិភាក្សាជាមួយអង្គការ Caritas Cambodia ពីការបន្តរៀបចំផែនការ ៥ ឆ្នាំបន្ត
- ប្រជុំបូកសរុបលទ្ធផលការងារខែកុម្ភៈ របស់នាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ
- ចូលរួមផ្សព្វផ្សាយលទ្ធផលសន្និបាតរបស់ក្រសួងនៅខេត្តកែប និងខេត្តព្រះសីហនុ
- រៀបចំកិច្ចប្រជុំប្រមូលទិន្នន័យស្តីពីកម្រងសេវាសាធារណៈក្រសួងអភិវឌ្ឍន៍ជនបទ
- ចូលរួមប្រជុំជាមួយលេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយរបស់ក្រសួងចំនួន ០២លើក
- ចុះតាមដានការអនុវត្តថវិកាកម្មវិធីនៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តចំនួន ០២ គឺ ខេត្តស្ទឹងត្រែង និងខេត្តបន្ទាយមានជ័យ
- ធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យផ្លូវជនបទ ប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរាជការ និងគេហទំព័រក្រសួងអភិវឌ្ឍន៍ជនបទ
- បានផ្តល់លិខិតគាំទ្របន្តអនុស្សរណៈនៃការយោគយល់គ្នារវាង អង្គការក្លែនអន្តរជាតិ ជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានផ្តល់លិខិតគាំទ្រកិច្ចព្រមព្រៀងសហប្រតិបត្តិការ រវាងក្រសួងអភិវឌ្ឍន៍ជនបទ ជូនអង្គការចំនួន ០២គឺ អង្គការស្អាតកម្ពុជា និងអង្គការ World Vision
- បានចុះពិនិត្យការងារជាក់ស្តែងរបស់អង្គការក្រៅរដ្ឋាភិបាលនៅក្នុងខេត្តរតនគិរី និងខេត្តក្រចេះ ។

### ២.២.៦. ការងារអធិការកិច្ច និងសវនកម្ម

- ចុះធ្វើសវនកម្មលើការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ថវិកាតាមកម្មវិធី ឆ្នាំ ២០១៩-២០២០ និងចុះពិនិត្យជាក់ស្តែងការងារសាងសង់ ជួសជុលអណ្តូងទឹក និងសាងសង់បង្គន់អនាម័យដោយប្រើប្រាស់ថវិការដ្ឋនៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តចំនួន ០២

រួមមាន ខេត្តមណ្ឌលគិរី និងខេត្តរតនគិរី
- ចុះសវនកម្មលើគម្រោងគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា និងអាស៊ីអាគ្នេយ៍ (CSADRMP) ក្នុងការិយបរិច្ឆេទឆ្នាំ ២០១៩-២០២០ នៅខេត្តចំនួន ០២ រួមមាន ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ
- ចុះធ្វើអធិការកិច្ចក្នុងការប្រើប្រាស់ថវិកាវដ្ដការិយបរិច្ឆេទ២០១៨ នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកណ្ដាល ។

**២.២.៧. ការងារអភិវឌ្ឍន៍ផ្លូវជនបទ និងមន្ទីរពិសោធន៍**

- បានរៀបចំសៀវភៅគម្រោងថែទាំខួបចំនួន ២៥ គម្រោង នៃគម្រោងសរុប ៣០ គម្រោង (ផ្លូវក្រាលក្រួសក្រហម ចំនួន ២០ គម្រោង និងផ្លូវក្រាលកៅស៊ូ DBST ចំនួន ០៥ គម្រោង)
- បានរៀបចំសៀវភៅគម្រោងថែទាំប្រចាំចំនួន៣១គម្រោង នៃគម្រោងសរុប ៤២ គម្រោង (ផ្លូវក្រាលក្រួសក្រហមចំនួន ១៨គម្រោង និងផ្លូវក្រាលកៅស៊ូ DBST ចំនួន ១៣ គម្រោង)
- បន្តការតាមដានត្រួតពិនិត្យវាយតម្លៃ និងសុពលភាពគម្រោងអនុវត្តក្នុងឆ្នាំ ២០១៩ ។

**២.២.៨. ការងារផ្គត់ផ្គង់ទឹកជនបទ**

- បានចូលរួមសិក្ខាសាលាពង្រឹងសមត្ថភាពតាមតំបន់ ស្ដីពីការសសេររបាយការណ៍ទិន្នន័យសម្រាប់ការគ្រប់គ្រងប្រព័ន្ធទិន្នន័យការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ
- បានចូលរួមប្រជុំពិភាក្សា អំពីការរៀបចំកម្មវិធីជ្រើសរើសគណៈកម្មការគ្រប់គ្រងប្រព័ន្ធចែកចាយទឹកសហគមន៍ ជាមួយមន្ទីរអភិវឌ្ឍន៍ជនបទខេត្តស្វាយរៀង
- ជួសជុលអណ្ដូងស្នប់ ចំនួន ១០ អណ្ដូង នៅខេត្តក្រចេះ និងខេត្តព្រះវិហារ ។

**២.២.៩. ការងារថែទាំសុខភាព និងអនាម័យជនបទ**

- បានចុះជ្រើសរើសភូមិគោលដៅ ដើម្បីអនុវត្តគម្រោងជំរុញការផ្ដល់សេវាអនាម័យជនបទ ឆ្នាំ២០២០ នៅខេត្តគោលដៅចំនួន១៣ គឺ ខេត្តក្រចេះ កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ ត្បូងឃ្មុំ ប៉ៃលិន ព្រះសីហនុ សៀមរាប កោះកុង កែប ឧត្តរមានជ័យ ព្រះវិហារ និងខេត្តស្វាយរៀង
- បានចុះចែកកន្ត្រៃដល់កុមារដែលមានអាយុក្រោម ៥ ឆ្នាំ ចំនួន ១០០ កន្ត្រៃ ដែលមានអ្នកចូលរួមចំនួន ១៥០ នាក់ក្នុងសហគមន៍ចំនួន ០៥ នៅសង្កាត់ទួលសង្កែ និងសង្កាត់ស្វាយប៉ាក រាជធានីភ្នំពេញ
- បានសហការជាមួយអង្គការ CRDT ចុះជំរុញការសាងសង់បង្គន់អនាម័យនៅភូមិចំនួន ០៣ ឃុំសៀមប៉ាង ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង
- បានសហការជាមួយ អង្គការ Plan International Cambodia ដើម្បីពិនិត្យផ្ទៀងផ្ទាត់ភូមិ ODF នៅ ក្នុងស្រុកអូរយ៉ាដាវ ខេត្តរតនគិរី ជាលទ្ធផលមានភូមិចំនួន ០៤ បានជាប់ជាភូមិ ODF ។

### ២.២.១០. ការងារអភិវឌ្ឍន៍សហគមន៍

- ចុះធ្វើបច្ចុប្បន្នភាព និងរៀបចំផែនការសកម្មភាពបណ្តុះបណ្តាល គ.អ.ភ (ថវិកាកម្មវិធី) នៅខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប និងខេត្តស្វាយរៀង
- ចុះពិនិត្យ និងតាមដានការអនុវត្តគម្រោងលើកកម្ពស់សន្តិសុខស្បៀងជាលក្ខណៈគ្រួសារ នៅខេត្តព្រះសីហនុ
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ បានរៀបចំឯកសារ និងកំណត់ឃុំគោលដៅសម្រាប់ផ្សព្វផ្សាយបើកវគ្គសិក្សាថ្មី ឆ្នាំ២០២០
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តតាកែវ បានធ្វើការផ្សព្វផ្សាយជ្រើសរើសសិស្សឲ្យចូលរៀនវគ្គបណ្តុះបណ្តាល ឆ្នាំ២០២០ ។

### ២.២.១១. ការងារបណ្តុះបណ្តាល

- មន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលក្នុងប្រទេស ចំនួន ៥៧ នាក់ ស្រី ០៦ នាក់
- មន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេស ចំនួន ០២ នាក់ ស្រី ០១ នាក់
- មន្ត្រីចូលរួមសិក្ខាសាលាក្នុងប្រទេស ចំនួន ៩៥ នាក់ ស្រី ០៧ នាក់
- បានរៀបចំឯកសារលិខិតចាត់បញ្ជូនមន្ត្រី ចំនួន ០៥ រូប ដើម្បីចូលរួមវគ្គបណ្តុះបណ្តាល
- ផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីអាហារូបករណ៍ និងវគ្គបណ្តុះបណ្តាល ចំនួន ០៤ លើក
- មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋានទាំង ១២ ខេត្ត រួមមាន ៖ ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តកំពង់ចាម ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តកំពត ខេត្តកំពង់ធំ ខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ បានរៀបចំឯកសារមួយចំនួន និងធ្វើការផ្សព្វផ្សាយសេចក្តីជូនដំណឹងជ្រើសរើសសិក្ខាកាមនៅតាមតំបន់គោលដៅ ព្រមទាំងធ្វើការផ្សព្វផ្សាយតាមវិទ្យុ FM របស់ខេត្ត សម្រាប់បើកវគ្គថ្មី វគ្គទី ១ ឆមាសទី ១ ឆ្នាំ២០២០ ។

### ២.២.១២. ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ

- គិតត្រឹមថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០២០ ប្រតិបត្តិករឥណទានជនបទដែលមន្ទីរអភិវឌ្ឍន៍ជនបទខេត្តអនុវត្តផ្ទាល់ និងសហការជាមួយដៃគូ និងសកម្មភាពការងារឥណទានដែលអនុវត្តដោយសហគមន៍សន្សំប្រាក់ បានផ្តល់ឥណទានសរុបចំនួន ៤ ១១៣ ១៦៧ ០៣៥ រៀល (បួនបីលានមួយរយដប់បីលានមួយរយហុកសិបប្រាំពីរពាន់សាមសិបប្រាំរៀល) ស្មើនឹង ១ ០៤៧ ៥១៧,៧២ ដុល្លារអាមេរិក (មួយលានសែសិបប្រាំពីរពាន់ប្រាំរយដប់ប្រាំពីរដុល្លារនិងចិតសិបពីរសេន) (១USD=៤០០០រៀល) មានអ្នកខ្ចីសរុបចំនួន ៤ ១៨៨ នាក់ នៅភូមិគោលដៅចំនួន ១៨៦ ភូមិ ៧២ ឃុំ ៣៣ ស្រុក ក្នុងខេត្តគោលដៅចំនួន ១៥
- បានចុះពិនិត្យមើលស្ថានភាពផ្សារជនបទ ដើម្បីសិក្សាលទ្ធភាពធ្វើការកែលម្អ
- បានចុះត្រួតពិនិត្យ និងវាយតម្លៃសកម្មភាពក្រោយពីវគ្គបណ្តុះបណ្តាលបច្ចេកទេសផលិតសាប៊ូលាងចាន នៅខេត្តសៀមរាប និងខេត្តកំពង់ឆ្នាំង ។

### ២.២.១៣. ការងារគ្រប់គ្រង និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច

- ចូលរួមជាវាគ្មិនកិត្តិយសជាមួយអង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច (ICSO) ក្នុងកិច្ចប្រជុំកែសម្រួលបទបញ្ជាផ្ទៃក្នុង របស់សហគមន៍មួយចំនួននៅខេត្តរតនគិរី ដែលមិនទាន់មានភាពស៊ីសង្វាក់គ្នា ដើម្បីជជែកពិភាក្សាពិនិត្យ និងកែសម្រួលនូវបទបញ្ជាផ្ទៃក្នុងឡើងវិញ និងពង្រឹងកិច្ចសហប្រតិបត្តិការ ភាពជាដៃគូរវាងរដ្ឋាភិបាល និងសង្គមស៊ីវិលឱ្យកាន់តែល្អ ។

### ២.២.១៤.ក្រុមការងារចុះមូលដ្ឋានតាមដានការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤

ក្នុងខែកុម្ភៈ ឆ្នាំ២០២០ នេះ លេខាធិការដ្ឋានក្រុមការងារចុះមូលដ្ឋានរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ទទួលបានសំណើ និងសំណូមពររបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន តាមរយៈមន្ទីរអភិវឌ្ឍន៍ជនបទរាជធានីខេត្ត សរុបចំនួន ១២ ករណី ក្នុងនោះក្រសួងបានដោះស្រាយជូនប្រជាពលរដ្ឋចំនួន ០៥ ករណី ។

### ២.២.១៥. ការងារយេនឌ័រ

- ចូលរួមវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពស្តីពី ការតាមដាន និងវាយតម្លៃការអនុវត្តអនុសញ្ញាស្តីពី ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ(ស៊ី-ដ)
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងគោនយោបាយជាតិ ស្តីពីសមត្ថភាពយេនឌ័រ និងផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ ឆ្នាំ ២០១៩-២០២៣
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ឧបករណ៍តាមដាន និងវាយតម្លៃពាក់ព័ន្ធសិទ្ធិស្ត្រី និងយេនឌ័រ
- ចូលរួមសិក្ខាសាលាថ្នាក់ជាតិ ស្តីពីផលប៉ះពាល់នៃកម្មវិធីស្តីពីការប្រែប្រួលអាកាសធាតុក្នុងប្រទេសកម្ពុជា៖ ភាពងាយរងគ្រោះ ភាពក្រីក្រ និងយេនឌ័រ ។

### ២.២.១៦. ការងារប្រយុទ្ធនឹងជំងឺអេដស៍

- ប្រជុំក្រុមការងារដើម្បីរៀបចំផែនការសម្រាប់អនុវត្តការងារ ឆ្នាំ២០២០ ។

## ២.៣. ការអនុវត្តគម្រោង និងកម្មវិធីសហប្រតិបត្តិការទ្វេភាគី និងពហុភាគី

### ២.៣.១. គម្រោងកែលម្អផ្លូវជនបទ ជំហាន ២

គិតត្រឹមដំណាច់ខែកុម្ភៈនេះ គម្រោងសម្រេចបាន ៖

- ខេត្តត្បូងឃ្មុំ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ ខ្សែ មានប្រវែងសរុប ១៩៣,៩ គ.ម សម្រេចបាន ១០០%
- ខេត្តតាកែវ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ ខ្សែ មានប្រវែងសរុប ១០៤,០៨ គ.ម សម្រេចបាន ៦៦,៦៦%
- ខេត្តកំពង់ស្ពឺ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ១០ ខ្សែ មានប្រវែងសរុប ១៦១,៦០គ.ម សម្រេចបាន ៧៨,២២%
- ខេត្តកំពង់ឆ្នាំង : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ ខ្សែ មានប្រវែងសរុប ១២៦,៣០ គ.ម សម្រេចបាន ៥៩,១៩%
- ខេត្តកំពង់ធំ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៤ ខ្សែ ប្រវែង ១១៣,៤០ គ.ម

សម្រេចបាន ៧៦,១៤%

- ខេត្តសៀមរាប : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៦ ខ្សែ មានប្រវែងសរុប ១២៦,២០ គ.ម សម្រេចបាន ៧១,០១%
- ខេត្តពោធិ៍សាត់ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ១០ ខ្សែ មានប្រវែងសរុប ១២៥,៥០ គ.ម សម្រេចបាន ១០០%
- ខេត្តបាត់ដំបង : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៨ ខ្សែ មានប្រវែងសរុប ១០១,២០ គ.ម សម្រេចបាន ១០០%
- ខេត្តបន្ទាយមានជ័យ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៥ ខ្សែ មានប្រវែងសរុប ៩០,៧០ គ.ម សម្រេចបាន ១០០%
- ខេត្តកំពង់ចាម : បាន និងកំពុងដំណើរការសាងសង់ផ្លូវក្រាលបេតុងចំនួន ០៦ ខ្សែ មានប្រវែងសរុប ៥០ គ.ម សម្រេចបាន ១០០%
- សាងសង់ប្រឡាយទឹកស្រោចស្រពដំណាំ និងមណ្ឌលសុខភាព នៅខេត្តត្បូងឃ្មុំ និងខេត្តកំពង់ចាម សម្រេចបាន ៥៤,៨៣ % ។

**២.៣.២. គម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទដំហានទី ៦**

ខែកុម្ភៈនេះ គម្រោងបាន និងកំពុងអនុវត្តនីតិវិធីលទ្ធកម្មសម្រាប់ការងារថែទាំផ្លូវជាលក្ខណៈខួបឆ្នាំ២០២០ ។

**២.៣.៣. គម្រោងសាច់ប្រាក់ពលកម្មសម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ និងការគាំទ្រកសិករ**

គិតត្រឹមខែកុម្ភៈនេះ គម្រោងបាន និងកំពុងអនុវត្តចំនួន ៦៤ គម្រោង ប្រវែង ១៧៣ ៨២៤ ម៉ែត្រ ក្នុងខេត្តគោលដៅចំនួន ១២ ក្នុងនោះបានបញ្ចប់ការងារ បានចំនួន ០៩ គម្រោង ប្រវែងសរុប ២២ ៩៣៩ ម៉ែត្រ នៅខេត្តកំពង់ស្ពឺ តាកែវ ពោធិ៍សាត់ ស្វាយរៀង និងខេត្តឧត្តរមានជ័យ ។

**២.៣.៤. គម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទទី ២**

- សង់បង្គន់សាធារណៈ និងអាងត្រងទឹកភ្លៀងសាធារណៈបានចំនួន ១០ កន្លែង និងសាងសង់ថ្នាលហាលលាមក សម្រេចបាន ១០០% នៅខេត្តបន្ទាយមានជ័យ
- ដឹកសម្ភារបង្គន់គ្រួសារចែកជូនប្រជាពលរដ្ឋ ហើយប្រជាពលរដ្ឋបានធ្វើបង្គន់អនាម័យរួចរាល់បានចំនួន ១ ៩៥៨ ខ្នងផ្ទះ និងសាងសង់បង្គន់ ABC សម្រេចបាន ៥% នៅខេត្តបន្ទាយមានជ័យ ។

**២.៣.៥. គម្រោងកិច្ចសហប្រតិបត្តិការមេគង្គឡានឆាង (Mekong Lancang Cooperation)**

- ចុះត្រួតពិនិត្យមើលសមិទ្ធផលនៃគម្រោងដំហានទី១ ការការងារសាងសង់បង្គន់ អនាម័យចំនួន ២៨ បង្គន់ ចង្ក្រានបច្ចេកទេសដុតអុសចំនួន ២០ ចង្ក្រាន និងស្លាកសញ្ញាផ្សព្វផ្សាយអនាម័យ និងបរិស្ថានចំនួន ៨០ ស្លាក
- ត្រួតពិនិត្យការអនុវត្តបច្ចេកទេសផលិតសាប៊ូតាមគ្រួសារដែលបានបណ្តុះបណ្តាលរួចនៅខេត្តគោលដៅចំនួន០៤ គឺ ខេត្តក្រចេះ ស្ទឹងត្រែង ព្រៃវែង និងខេត្តកណ្តាល
- ចុះត្រួតពិនិត្យការងារសាងសង់ផ្សារជនបទ ពិនិត្យទីតាំង និងបញ្ហាប្រឈម

- ប្រជុំពិភាក្សាជាមួយអជ្ញាធរ ០៤ ស្រុក នៃខេត្តកំពង់ឆ្នាំងលើនីតិវិធីគ្រប់គ្រងរដ្ឋបាលផ្សារជនបទដែលកំពុងសាងសង់
- រៀបចំ និងបង្កើតផែនការសកម្មភាពសហករអាជីវកម្មចំនួន ០៥ កន្លែង ។

**២.៣.៦. គម្រោងសហប្រតិបត្តិការមេគង្គ-គង្គា**

- សិក្សាទិន្នន័យអាសេនិកនៅខេត្តគោលដៅចំនួន ០៤ គឺខេត្តពោធិ៍សាត់ កំពង់ឆ្នាំង បាត់ដំបង និងខេត្តសៀមរាប
- ប្រជុំបច្ចេកទេសត្រួតពិនិត្យតំបន់ដែលមានជាតិអាសេនិកក្នុងទឹក
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយសុខភាព ទឹកស្អាត អនាម័យ នៅឃុំតែ្បងខ្ពស់ ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ចំនួន ០២ លើក
- បណ្តុះបណ្តាលបច្ចេកទេសផលិតសាប៊ូនៅខេត្តព្រៃវែង ចំនួន ០១ វគ្គ មានអ្នកចូលរួម ៦៥ នាក់
- សាងសង់បង្គន់អនាម័យបានចំនួន ២០ នៅភូមិថ្មីខ្មែរ និងភូមិវាលតាគីង ឃុំតែ្បងខ្ពស់ ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ។

**២.៣.៧. គម្រោងគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា និងអាស៊ីអាគ្នេយ៍**

គម្រោងគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា និងអាស៊ីអាគ្នេយ៍ គឺជាគម្រោងក្រោមហិរញ្ញប្បទានសហប្រតិបត្តិការពីធនាគារពិភពលោក និងបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានថវិកាសរុប ៦២,៥ លានដុល្លារអាមេរិក ក្រោមការគ្រប់គ្រង និងដឹកនាំដោយក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ គម្រោងនឹងត្រូវធ្វើការស្ថាបនាផ្លូវក្រាលកៅស៊ូពីរជាន់ DBST និងប្រភេទផ្លូវបេតុងចំពោះតំបន់មានទឹកលិច ប្រវែងសរុបចំនួន ២៥៥ គីឡូម៉ែត្រ ស្ពាន ប្រវែង ១០០ ម៉ែត្រ ចំនួន ០១ ព្រមទាំងសំណង់សិល្បការ្យជាច្រើនទៀត នៅក្នុងខេត្តគោលដៅរបស់គម្រោងចំនួន ០៦ រួមមានខេត្តស្ទឹងត្រែង ខេត្តក្រចេះ ខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តកណ្តាល និងខេត្តសៀមរាប។ ក្នុងខែកុម្ភៈនេះ គម្រោងសម្រេចបាន ៖

- បានបញ្ចប់ការដេញថ្លៃ កញ្ចប់ទី ១ សម្រាប់កាស្ថាបនាផ្លូវប្រវែង ៥០គីឡូម៉ែត្រ នៅក្នុងខេត្តកណ្តាល ជាប្រភេទផ្លូវក្រាលកៅស៊ូពីរជាន់ (DBST) និងបេតុង និងគ្រោងចាប់ផ្តើមការសោងសង់នៅខែមេសាខាងមុខ
- បានដាក់ដេញថ្លៃ កញ្ចប់ទី ២ សម្រាប់ការស្ថាបនាផ្លូវប្រវែង ៤៥ គីឡូម៉ែត្រ នៅក្នុងខេត្តចំនួន ០២ រួមមាន ខេត្តក្រចេះ និងខេត្តស្ទឹងត្រែង ជាប្រភេទផ្លូវក្រាលកៅស៊ូពីរជាន់ (DBST) និងបេតុង
- គ្រោងនឹងដាក់ដេញថ្លៃ កញ្ចប់ទី ៣ សម្រាប់ការស្ថាបនាផ្លូវប្រវែង ១៦០ គីឡូម៉ែត្រ នៅក្នុងខេត្តចំនួន ០៣ រួមមាន ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ និងខេត្តសៀមរាប ជាប្រភេទផ្លូវក្រាលកៅស៊ូពីរជាន់ (DBST) និងបេតុង ។

## ៣. ទិសដៅបន្ត

### ៣.១. បញ្ហាប្រឈម

- ឧបករណ៍ពិសោធន៍មួយចំនួនពុំទាន់បានបណ្តុះបណ្តាលដល់វិស្វករ និងមន្ត្រីជំនាញបម្រើការងារនៅមន្ទីរពិសោធន៍
- ទាមទារពេលវេលាវែង ដើម្បីជំរុញការផ្លាស់ប្តូរទម្លាប់របស់ប្រជាជន ក្នុងការប្រតិបត្តិអនាម័យល្អ
- សមត្ថភាពចូលរួមផ្តល់សេវារបស់វិស័យឯកជននៅមានកម្រិត
- តំបន់ខ្លះខ្វះទឹកដែលអាចប៉ះពាល់ដល់ស្ថានភាពអនាម័យ
- ទម្លាប់សង្គមក្នុងការបន្ទោរបង់ពាសវាលពាសកាល មិនទម្លាប់ផឹកទឹកស្អាត និងការលាងដៃឲ្យបានត្រឹមត្រូវ ខ្វះការយល់ដឹង ដែលនាំឲ្យកម្រិតវិនិយោគពីគ្រួសារទាប
- ទីផ្សារអនាម័យនៅមានកម្រិត (បច្ចេកវិទ្យា ផលិតផល ការផ្គត់ផ្គង់បរិក្ខារអនាម័យ)
- ការចូលរួមរបស់សហគមន៍ក្នុងការសម្រេចចិត្តលើការងារអភិវឌ្ឍន៍នៅមានកម្រិត
- ប្រជាពលរដ្ឋនៅតាមមូលដ្ឋានមួយចំនួនមានជីវភាពខ្វះខាត ជាហេតុនាំឲ្យមានការធ្វើចំណាកស្រុកទៅប្រកបមុខរបរនៅប្រទេសជិតខាង ដែលធ្វើឲ្យប៉ះពាល់ដល់ដំណើរការនៃការអនុវត្តសកម្មភាពអភិវឌ្ឍន៍នៅមូលដ្ឋានរបស់ខ្លួន
- គ.អ.ភ ពុំមានស្នាក់ការសម្រាប់ធ្វើការងារ
- ស្ថាប័ន ឬអង្គការមួយចំនួន មិនបានប្រើប្រាស់ គ.អ.ភ ហើយបានបង្កើតជនបង្គោលផ្សេងៗពី គ.អ.ភ ។

### ៣.២. ទិសដៅតាមអង្គភាព

- បន្តចុះធ្វើអធិការកិច្ចជាប្រចាំទៅលើអង្គភាពក្រោមឱវាទក្រសួងអភិវឌ្ឍន៍ជនបទ
- រៀបចំផែនការវិនិយោគសាធារណៈ និងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២១-២០២៣
- រៀបចំពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពឯកសារគតិយុត្តសម្រាប់វិស័យផ្គត់ផ្គង់ទឹកស្អាតជនបទ
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃសំណង់ប្រព័ន្ធផ្គត់ផ្គង់ទឹកជនបទ ទូទាំង ២៥ រាជធានី ខេត្ត
- ផ្សព្វផ្សាយផែនការសកម្មភាពជាតិ ស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ
- បន្តការរៀបចំផែនការ និងកិច្ចសហការនានាជាមួយអង្គការដៃគូនានាលើកម្មវិធីលើកកម្ពស់អនាម័យជនបទ
- បន្តសហការសាកល្បងការផ្ទេរមុខងារអនាម័យទៅរដ្ឋបាលថ្នាក់ស្រុកទាំង ១៥ ក្នុងខេត្ត គោលដៅទាំង ០៣ គឺខេត្តត្បូងឃ្មុំ ខេត្តកំពង់ស្ពឺ និងខេត្តកំពង់ឆ្នាំង
- ត្រៀមរៀបចំពិនិត្យសារឡើងវិញនូវផែនការសកម្មភាពជាតិ ជំហានទី ១ (២០១៤-២០១៨) និងរៀបចំធ្វើផែនការសកម្មភាពជាតិជំហានទី ២ ស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យជនបទ (២០១៩-២០២៣)

- បន្តកិច្ចសហប្រតិបត្តិការជាមួយអង្គការដៃគូអភិវឌ្ឍន៍នានា និងស្ថាប័នពាក់ព័ន្ធដើម្បីបញ្ជូនមន្ត្រីឲ្យចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងទស្សនកិច្ចសិក្សា ដើម្បីលើកកម្ពស់សមត្ថភាពមន្ត្រី
- សិក្សាភូមិគោលដៅដើម្បីរៀបចំកំណត់អត្តសញ្ញាណជនជាតិដើមភាគតិច
- បន្តការចុះកំណត់អត្តសញ្ញាណ បទបញ្ជាផ្ទៃក្នុង និងលក្ខន្តិកៈរបស់ក្រុមជនជាតិដើមភាគតិច ។

## ៤.សេចក្តីសន្និដ្ឋាន

យោងតាមរបាយការណ៍ខាងលើបង្ហាញថា ក្រសួងទើបអនុវត្តផែនការបានតិចតួចនៅឡើយ តែការងារកែទម្រង់ផ្សេងៗមានសកម្មភាពច្រើនក្នុងខែនេះ ដើម្បីចាត់វិធានការតាមការណែនាំរបស់រាជរដ្ឋាភិបាល ។ ដោយឡែកកិច្ចសហការជាមួយដៃគូជាទ្វេភាគី ពហុភាគី និងអង្គការក្រៅរដ្ឋាភិបាលមានសកម្មភាពច្រើនគួរកត់សម្គាល់ ដែលកំពុងជួយជំរុញការអនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្រក្រសួងឲ្យទទួលបានជោគជ័យ ។ ក្រសួងនឹងបន្តខិតខំប្រឹងប្រែងថែមទៀតក្នុងការធ្វើឲ្យសម្រេចបានតាមផែនការដែលបានគ្រោងទុកដើម្បីរួមចំណែកកែលម្អស្ថានភាពជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឲ្យបានកាន់តែល្អប្រសើរថែមទៀត ៕

រដ្ឋមន្ត្រី

បណ្ឌិត អ៊ុក រ៉ាប៊ុន